ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋាន

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែធ្នូ ឆ្នាំ២០២៣ និងទិសដៅការងារខែមករា ឆ្នាំ២០២៤

នៅក្នុងខែធ្នូនេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបំពេញការងារលើគ្រប់វិស័យ ដើម្បីផ្តល់សេវាជូនថ្នាក់ដឹកនាំ និងសមាជិក សមាជិកាព្រឹទ្ធសភា ក្នុងការអនុវត្តមុខងាររបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

**១- មុខងារតាមដានការអនុវត្តច្បាប់**

-បានរៀបចំចាត់ចែង និងផ្តល់សេវាជូនគណៈប្រតិភូគណៈកម្មការទី៥ព្រឹទ្ធសភា អញ្ជើញចុះសិក្សាឈ្វេងយល់ពីស្ថានភាពមជ្ឈមណ្ឌលកសុកម្ម និងកំពង់ផែពហុបំណងរបស់ក្រុមហ៊ុនកំពតឡូជីស្ទីកអេនផត ៦.ក និងបានអញ្ជើញទស្សនកិច្ចរមណីយដ្ឋានភ្នំបូកគោ នៅខេត្តកំពត។

**២-មុខងារតំណាង**

**-បានរៀបចំចាត់ចែង និងផ្តល់សេវាជូន៖**

- សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភាបាន៖
  - អញ្ជើញចូលរួមថ្វាយ និងទទួលព្រះរាជដំណើរ ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ស្តេចយាងបំពេញព្រះរាជទស្សនកិច្ចផ្លូវការ នៅសាធារណរដ្ឋប្រជាមានិតចិន
  - អញ្ជើញជាព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់របស់ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ក្នុងពិធីបើកអនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេស លើកទី៣១ ប្រចាំឆ្នាំ២០២៣ នៅសាកលវិទ្យាស្ថានជាតិអប់រំ រាជធានីភ្នំពេញ
  - អញ្ជើញចូលរួមរំលែកទុក្ខជាមួយក្រុមគ្រួសារសព និងគោរពវិញ្ញាណក្ខន្ធសព ឯកឧត្តម ឡុង ពៅប្រាជ្ញា ទីប្រឹក្សាផ្ទាល់សម្តេចប្រធានព្រឹទ្ធសភា និងសពសីលវិសុទ្ធសិរីវចនា អគ្គមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៍ នាង ហ៊ុច នៅរាជធានីភ្នំពេញ



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443, ទូរសារ: (855 23) 211 446, E-mail: oumsarith_sgsenate@gmail.com, oumsarith_sgsenate@yahoo.com

- អញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខសមាជិក សមាជិកាក្រុមប្រឹក្សាសង្កាត់ ទូទាំងខណ្ឌព្រែកព្នៅ ខណ្ឌសែនសុខ និងខណ្ឌកំបូល រាជធានីភ្នំពេញ
- អញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខមន្ត្រី អាជ្ញាធរ និងកងកម្លាំងប៉ុស្តិ៍ នៅខេត្តត្បូងឃ្មុំ ខេត្តកំពង់ស្ពឺ និងខេត្តកែប

❖ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ស៊ីម កា អនុប្រធានទី១ព្រឹទ្ធសភា បានអញ្ជើញចុះជួបសំណេះ-សំណាលជាមួយអាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋ នៅរាជធានីភ្នំពេញ និងតាមបណ្ដាខេត្តក្រុងនានា ចំនួន ០៨លើក

❖ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ស៊ីម កា អនុប្រធានទី១ព្រឹទ្ធសភា, សមាជិក សមាជិកាព្រឹទ្ធសភា និងឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញចូលរួមមីទិញអបអរសាទរខួបអនុស្សាវរីយ៍លើកទី៤៥ ទិវាកំណើតរណសិរ្សសាមគ្គី អភិវឌ្ឍន៍មាតុភូមិកម្ពុជា នៅសាលសន្និសីទ និងសាលមហោស្រពកោះពេជ្រ រាជធានីភ្នំពេញ និងនៅខេត្តកំពង់ធំ

❖ ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន អនុប្រធានទី២ព្រឹទ្ធសភា បានចាត់ឱ្យក្រុមការងារដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះទៅពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ នៅខេត្តតាកែវ

❖ លោកជំទាវកិត្តិនីតិកោសលបណ្ឌិត ទី ប៉ូវ៉ាស៊ី ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា បានអញ្ជើញប្រគល់អំពូលភ្លើងសូឡាដល់សាលាបឋមសិក្សាវាលនិទ្រា នៅស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់

❖ លោកជំទាវ មាន សំអាន ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា និងលោកជំទាវ មុំ សណ្ដាប់ លេខាធិការគណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញជាកិត្តិយសធ្វើរបាយការណ៍បូកសរុបលទ្ធផលសិក្ខាសាលាពិគ្រោះយោបល់ និងធ្វើបទបង្ហាញស្តីពី "ការបង្ការ និងគ្រប់គ្រងជំងឺមិនឆ្លង និងវិធានការដើម្បីកាត់បន្ថយគម្លាតយេនឌ័រដែលបណ្ដាលមកពីជំងឺមិនឆ្លង" នៅសណ្ឋាគារកាំបូឌីយ៉ាណា រាជធានីភ្នំពេញ

❖ សមាជិក សមាជិកាព្រឹទ្ធសភា បាន៖

- អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីផ្សេងៗ ចំនួន ០៤លើក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅរាជធានីភ្នំពេញ ខេត្តកែប និងខេត្តព្រះសីហនុ
- អញ្ជើញជាកិត្តិយសក្នុងពិធីអបអរសាទរទិវាជាតិប្រឆាំងការជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០២៣ នៅសាលមហោស្រពកោះពេជ្រ រាជធានីភ្នំពេញ

❖ ដោយឡែកសមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ ក្រុមគ្រូពេទ្យ អតីតមន្ត្រីរាជការជានិវត្តជន អតីតយុទ្ធជន យុវជន-យុវនារី ក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន នាយប៉ុស្តិ៍នគរបាលរដ្ឋបាល និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីពង្រឹងតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់នៅមូលដ្ឋាន ឈ្វេងយល់អំពីវឌ្ឍនភាពការងារ ការងារសន្តិសុខ សណ្ដាប់ធ្នាប់ ការអភិវឌ្ឍមូលដ្ឋាន ការផ្ដល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងគោលនយោបាយភូមិ-ឃុំ មានសុវត្ថិភាព ពិនិត្យហេដ្ឋារចនាសម្ព័ន្ធ ដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានា នៅរាជធានីភ្នំពេញ និងតាមបណ្ដាខេត្ត ក្រុងនានា ចំនួន ៤០លើក ព្រមទាំងបានអញ្ជើញជាអធិបតីក្នុងពិធីសម្ពោធសមិទ្ធផលនានា និងចូលរួមជាកិត្តិយសក្នុងពិធីផ្សេងៗ ចំនួន ៩៤លើក

-បានទទួលដំណើរទស្សនកិច្ច និងធ្វើបទបង្ហាញស្ដីពី រចនាសម្ព័ន្ធ តួនាទី ភារកិច្ចរបស់ព្រឹទ្ធសភា ចំនួន ០២លើក ជូនៈ

- សិក្ខាកាមមកពីសភាថៃ ឡាវ និងកម្ពុជា ចំនួន ២៤នាក់
- មន្ត្រីមកពីពុទ្ធសាសនបណ្ឌិត្យ ចំនួន ១៧នាក់

-បានរៀបចំ និងចាត់ចែងបញ្ជូនសារលិខិតជូនពររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា គោរពជូនសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** ប្រធានកាកបាទក្រហមកម្ពុជា ក្នុងឱកាសដ៏មង្គលសួស្ដី នៃពិធីចម្រើនជន្មាយុរបស់សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត

-ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានផ្ញើសារ និងប័ណ្ណជូនពរអបអរឆ្នាំថ្មីសកល២០២៤ ជូនថ្នាក់ដឹកនាំជាន់ខ្ពស់ជាតិ-អន្តរជាតិ និងអង្គទូតនានា

-បានរៀបចំចាត់ចែងជូនសមាជិក សមាជិកាព្រឹទ្ធសភា និងគណៈប្រតិភូអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អញ្ជើញចូលរួមគោរពវិញ្ញាណក្ខន្ធ ព្រមទាំងបានចាត់ចែងបញ្ជូនសារលិខិតរំលែកទុក្ខជូនៈ

- ឯកឧត្តម **សួន សុធី** ព្រមទាំងក្រុមគ្រួសារ ចំពោះមរណភាពលោកជំទាវ **តិច ដារ៉ាន់**
- លោក **ងួន សុគន្ធារិទ្ធ** ព្រមទាំងក្រុមគ្រួសារ ចំពោះមរណភាពលោកឱសថការីឧត្តម **យាន អ៊ីស្រេង**
- លោក **ម៉ែន ខេមរៈ** ព្រមទាំងក្រុមគ្រួសារ ចំពោះមរណភាពឧបាសិកា **ទឹម វណ្ណឿន**
- លោក **ណេង សក្កដា** ព្រមទាំងក្រុមគ្រួសារ ចំពោះមរណភាពឧបាសិកា **នូ ស៊ីថុន**
- ក្រុមគ្រួសារលោក **អេង វេង** និវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បានទទួលមន្ត្រីរាជការ សិស្ស និស្សិត និងសាធារណជនចូលអានសៀវភៅនៅបណ្ណាល័យព្រឹទ្ធសភា ចំនួន ៣០នាក់

-បានផ្ដល់សៀវភៅដែលបោះពុម្ពដោយអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជូននិស្សិតនៃសាកលវិទ្យាល័យអាស៊ី-អឺរ៉ុប, សាលាអន្តរជាតិប៊េសេរ៉ េ និងអនុវិទ្យាល័យលលក ខេត្តកំពង់ស្ពឺ ចំនួន ៣១៧ក្បាល

-បានរៀបចំផលិតខ្សែវីដេអូសមិទ្ធផលរបស់ព្រឹទ្ធសភា ចំនួន ០២ខ្សែ ស្តីពីៈ

- សមិទ្ធផលការងាររបស់គណៈកម្មការទី៥ព្រឹទ្ធសភា នីតិកាលទី៤ (ឆ្នាំ២០១៨-២០២៤)
- សមិទ្ធផលការងាររបស់សមាជិកាព្រឹទ្ធសភា នីតិកាលទី៤ (ឆ្នាំ២០១៨-២០២៤)

-បានផលិត និងផ្សព្វផ្សាយទស្សនាវដ្តីប្រចាំខែធ្នូ ឆ្នាំ២០២៣ ចំនួន ៨០០ក្បាល

-បានធ្វើបច្ចុប្បន្នភាព រៀបចំផលិត និងផ្សព្វផ្សាយៈ

- ប្រតិទិនព្រឹទ្ធសភា ឆ្នាំ២០២៤ ចំនួន ២,៥០០ក្បាល
- សៀវភៅទិនានុលេខន៍ព្រឹទ្ធសភា ឆ្នាំ២០២៤ ចំនួន ១,០០០ក្បាល

-បានទទួលពាក្យបណ្តឹង ចំនួន ០៤ករណី កំពុងពិនិត្យសិក្សា ចំនួន ០៨ករណី និងទទួលឯកសារជូនជ្រាបពីក្រសួង ស្ថាប័នពាក់ព័ន្ធចម្លងជូនមកគណៈកម្មការ ចំនួន ០២ករណី។

**៣-មុខងារសហប្រតិបត្តិការអន្តរជាតិ**

-បានរៀបចំចាត់ចែង និងផ្តល់សេវាជូន សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងពិធីជំនួបសម្តែងការគួរសម និងសវនាការជាមួយឯកឧត្តម **កៅ យុនឡុង** អនុប្រធានសភាប្រឹក្សានយោបាយប្រជាជនចិន នៃសាធារណរដ្ឋប្រជាមានិតចិន និងជាប្រធានមូលនិធិដើម្បីសន្តិភាព និងការអភិវឌ្ឍ

-បានរៀបចំចាត់ចែង និងផ្តល់សេវាជូន **ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន** អនុប្រធានទី២ព្រឹទ្ធសភាៈ

- ❖ អញ្ជើញជាអធិបតីក្នុងពិធីប្រកាសដាក់ឱ្យដំណើរការកិច្ចសហប្រតិបត្តិការលើកកម្ពស់ជីវភាពមិត្តភាពកម្ពុជា-ចិន ដើម្បីផលប្រយោជន៍ប្រជាជន ក្រោមក្របខ័ណ្ឌប្រតិបត្តិការជំរុញការតភ្ជាប់ប្រជាជន និងប្រជាជន តាមផ្លូវសូត្រជាមួយឯកឧត្តម **កៅ យុនឡុង** អនុប្រធានសភាប្រឹក្សានយោបាយប្រជាជនចិន នៃសាធារណរដ្ឋប្រជាមានិតចិន និងជាប្រធានមូលនិធិដើម្បីសន្តិភាព និងការអភិវឌ្ឍ ព្រមទាំងបានរៀបចំពិធីលៀងសាយភោជនផ្លូវការជូនជាកិត្តិយសដល់ឯកឧត្តម **កៅ យុនឡុង** និងគណៈប្រតិភូ នៅសណ្ឋាគារសូហ្វីតែលភ្នំពេញភូគីត្រា
- ❖ អញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភា គោរពវិញ្ញាណក្ខន្ធព្រះមហាក្សត្រ Sheikh NAWAF AL-AHMADAL-JABER AL-SABAH នៃរដ្ឋគុយវ៉ែត នៅស្ថានទូតគុយវ៉ែត ប្រចាំព្រះរាជាណាចក្រកម្ពុជា

-បានរៀបចំ សម្របសម្រួលបែបបទ ផ្តល់សេវា និងអមដំណើរសមាជិក សមាជិកាព្រឹទ្ធសភាអញ្ជើញចូលរួមកិច្ចប្រជុំអន្តរជាតិ សិក្ខាសាលា និងកម្មវិធីនានា ព្រមទាំងរៀបចំពិធីផ្សេងៗ រួមមានៈ

- ❖ កិច្ចប្រជុំកំពូលសភា កម្ពុជា-ឡាវ-វៀតណាម (CLV) លើកទី១ ស្តីពី ការពង្រឹងតួនាទីសភាក្នុងការលើកកម្ពស់កិច្ចសហប្រតិបត្តិការគ្រប់ជ្រុងជ្រោយនៃប្រទេសទាំងបី នៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

- ❖ ពិធីទទួល និងជូនដំណើរឯកឧត្តម កៅ យុនឡុង អនុប្រធានសភាប្រឹក្សានយោបាយប្រជាជនចិន នៃសាធារណរដ្ឋប្រជាមានិតចិន និងជាប្រធានមូលនិធិដើម្បីសន្តិភាព និងការអភិវឌ្ឍ អញ្ជើញមកទស្សនកិច្ចផ្លូវការនៅព្រះរាជាណាចក្រកម្ពុជា
- ❖ សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិសម្រាប់ការពិនិត្យជាសកលតាមកាលកំណត់(UPR) នៅសណ្ឋាគារកាំបូឌីយ៉ាណា
- ❖ កម្មវិធីពិភាក្សា និងពិគ្រោះយោបល់កម្រិតខ្ពស់ជាមួយដៃគូអភិវឌ្ឍន៍អន្តរជាតិ នៅសណ្ឋាគារសូហ្វីតែលភ្នំពេញភូគីត្រា
- ❖ រៀបចំពិធីបើក និងបិទសិក្ខាសាលាការផ្លាស់ប្តូរព័ត៌មានក្នុងស្ថាប័ន "អត្រានុកូលដ្ឋាន និងការចុះសំបុត្រកំណើតនៅកម្ពុជា" រួមគ្នារវាងសមាជិកព្រឹទ្ធសភា និងរដ្ឋសភា ដោយសហការជាមួយលេខាធិការដ្ឋាន(APF) ព្រមទាំងបានរៀបចំពិធីលៀងស្វាគមន៍ជូនគណៈប្រតិភូនៃសភាប្រើភាសាបារាំង(APF) នៅវិមានព្រឹទ្ធសភា
- ❖ រៀបចំពិធីពិសាអាហារសាមគ្គីជាមួយលោកជំទាវ **Devyani Uttam Khobragade** ឯកអគ្គរដ្ឋទូតឥណ្ឌា ប្រចាំព្រះរាជាណាចក្រកម្ពុជា និងសហការី ដើម្បីពង្រឹងពង្រីកចំណងមិត្តភាព កិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ (កម្ពុជា-ឥណ្ឌា) នៅភោជនីយដ្ឋានក្រវ៉ាញ រាជធានីភ្នំពេញ

-បានរៀបចំចាត់ចែង និងផ្តល់សេវាជូនសមាជិក សមាជិកាព្រឹទ្ធសភា ក្នុងពិធីជំនួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយគណៈប្រតិភូរដ្ឋសភាកូរ៉េ, គណៈប្រតិភូមកពីវេទិកាភាពជាដៃគូដើម្បីបញ្ចប់ជំងឺរបេងនៃប្រទេសកាហ្សាក់ស្ថាន, ថ្នាក់ដឹកនាំនៃក្រុមហ៊ុនផាប៉ាហ្គន និងក្រុមប្រឹក្សាភិបាលនៃសាកលវិទ្យាល័យអន្តរជាតិផាប៉ាហ្គន, ប្រធានក្រុមហ៊ុន NDN.kh.group និងសហការី, លោក **William Van De Put** និង **Dr Alexander Evangroen** ជនជាតិហូឡង់

-បានសហការជាមួយវិទ្យុមិត្តភាពកម្ពុជា-ចិន និងសមាគមអ្នកស្រាវជ្រាវវឌ្ឍនភាពកម្ពុជា-ចិន រៀបចំពិធីតាំងពិព័រណ៍សមិទ្ធផលខួប១០ឆ្នាំ នៃការរួមគ្នាកសាងខ្សែក្រវ៉ាត់ និងផ្លូវ រវាងកម្ពុជា-ចិន និងកិច្ចសំណេះសំណាលជាមួយប្រិយមិត្ត អបអរសាទរខួបគម្រប់១៩ឆ្នាំនៃការបង្កើតវិទ្យុមិត្តភាពកម្ពុជា-ចិន នៅសាលសិក្ខាសាលាបណ្ណាល័យព្រឹទ្ធសភា

-បានរៀបចំពិធីប្រគល់-ទទួលអំណោយជាសម្ភារការិយាល័យ ដែលជាជំនួយរបស់រដ្ឋសភានៃសាធារណរដ្ឋសង្គមនិយមវៀតណាម

-បានសហការ និងទំនាក់ទំនងជាមួយស្ថានទូតសិង្ហបុរី, ស្ថានទូតចិន, ស្ថានទូតម៉ាឡេស៊ី, ស្ថានទូតព្រុយណេ, ស្ថានទូតឥណ្ឌា, ស្ថានទូតវៀតណាម, ទីស្តីការគណៈរដ្ឋមន្ត្រី, អង្គការមូលនិធិអាស៊ី, អង្គការតម្លាភាពកម្ពុជា (TI Cambodia), មជ្ឈមណ្ឌលសភាអាស៊ី (PCAsia), បណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថល

កម្ពុជា(CADT), វិទ្យាស្ថានវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍, វិទ្យាស្ថាន Proseth, វិទ្យាស្ថាន Sunrise, វិទ្យាស្ថាន SalaCyber, វិទ្យាស្ថានជាតិស្ថិតិ(NIS), សមាគមអ្នកស្រាវជ្រាវវឌ្ឍនភាពកម្ពុជា-ចិន, សមាគមនាវាយុវជនអាស៊ីអាគ្នេយ៍, វិទ្យុមិត្តភាពកម្ពុជា-ចិន, ក្រុមហ៊ុន KOHA និងក្រសួង ស្ថាប័ន បណ្ណាល័យនានា ដើម្បីសម្រួលដល់កិច្ចការអន្តរជាតិ និងស្នើសុំអាហារូបករណ៍ វគ្គបណ្តុះបណ្តាល ជំនួយ ព្រមទាំងការរៀបចំពិធីផ្សេងៗ។

## ៤-មុខងារអភិវឌ្ឍន៍ស្ថាប័ន

### ៤.១-ប្រជុំការងារសំខាន់ៗ និងកិច្ចពិភាក្សាការងារផ្សេងៗ៖

-ឯកឧត្តម អ៊ុំ សារិទ្ធ អគ្គលេខាធិការព្រឹទ្ធសភាបានទទួលជួបពិភាក្សាការងារជាមួយ ឯកឧត្តម ភោគ ចន្ថា ទីប្រឹក្សាសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងជាមេបញ្ជាការរងអង្គរក្ស ដើម្បីពិនិត្យ និងពិភាក្សាលើផែនការរៀបចំពិធីបើកសម័យប្រជុំដំបូងព្រឹទ្ធសភា នីតិកាលទី៥

-បានប្រជុំការងារសំខាន់ៗ ចំនួន ០៦លើក ស្តីពី៖

- ត្រៀមរៀបចំពិធីបើកសម័យប្រជុំដំបូងព្រឹទ្ធសភា នីតិកាលទី៥ និងការចងក្រងឯកសារស្តីពីសេវាសំខាន់ៗសម្រាប់សមាជិកព្រឹទ្ធសភា
- ការងារលទ្ធកម្មសាធារណៈ
- ពិនិត្យពិភាក្សាលើការអនុវត្តកម្មវិធីផ្តល់ប្រាក់ឧបត្ថម្ភជូនមន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យាជាស្ត្រីមានផ្ទៃពោះ និងកូនរហូតដល់អាយុ០២ឆ្នាំ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- បូកសរុបលទ្ធផលការងាររបស់គណៈកម្មការមូលដ្ឋានអគ្គលេខាធិការដ្ឋានព្រឹទ្ធសភានៃសមាគមសង្គហៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ ប្រចាំឆ្នាំ២០២៣ និងលើកទិសដៅការងារឆ្នាំ២០២៤
- វាយតម្លៃស្ថានភាពមន្ត្រីរាជការបាត់បង់សម្បទាវិជ្ជាជីវៈ និងពិនិត្យលក្ខណៈសម្បត្តិបេក្ខជនដែលត្រូវស្នើសុំគ្រឿងឥស្សរិយយសជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាសម្រាប់ឆ្នាំ២០២៣
- ផ្សព្វផ្សាយរបាយការណ៍ស្តីពី លទ្ធផលនៃការស្ទង់មតិអំពីភាពពេញចិត្តចំពោះការងាររបស់មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បានស្តាប់បទបង្ហាញស្តីពី របៀបប្រើបណ្ណាល័យអេឡិចត្រូនិចរបស់មជ្ឈមណ្ឌលសភាអាស៊ី ។

### ៤.២-ការងាររដ្ឋបាល និងហិរញ្ញវត្ថុ

-បានបើកប្រាក់បៀវត្សប្រចាំខែធ្នូ ឆ្នាំ២០២៣ និងប្រាក់ឧបត្ថម្ភផ្សេងៗជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា ទីប្រឹក្សា ជំនួយការ អ្នកបើកបរ និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងគោលការណ៍ថ្មីអំពីការផ្តល់របបផ្សេងៗតាមរយៈធនាគារ ព្រមទាំងបែបបទចាំបាច់សម្រាប់ខែមករា ឆ្នាំ២០២៤

-បានតាមដានការស្នើសុំឥណទានបន្ថែម និងបុរេប្រទានពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលត្រូវអនុវត្តពីរជំហានៈ (៤០% និង៦០%) ដើម្បីអនុវត្តការងារសំណង់សំខាន់ៗ និងការត្រៀមលក្ខណៈសម្រាប់ការបើកនីតិកាលទី៥ ព្រឹទ្ធសភា

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានផ្តល់បុរេប្រទានថវិកា ចំនួន ២,០៦៦,២៨០,០០០រៀល គឺស្មើនឹង ៤០% នៃទឹកប្រាក់ ចំនួន ៥,១៦៥,០០០,០០០រៀល សម្រាប់សាងសង់ជណ្តើរយន្ត ចំនួន ០៤គ្រឿង ផ្លាស់ប្តូរម៉ាស៊ីនត្រជាក់ ទូរទឹកកក សង្ហារិម និងជួសជុលសាលប្រជុំពេញអង្គព្រឹទ្ធសភា

-បានប្រជុំ និងរៀបចំការងារហិរញ្ញវត្ថុ ឆ្នាំ២០២៤ របស់ព្រឹទ្ធសភា

-បានចូលរួមប្រជុំ សិក្ខាសាលា ពិគ្រោះយោបល់លើការងារពាក់ព័ន្ធនឹងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ ចំនួន ០៦លើក

-បានតាមដានគោលការណ៍ និងព័ត៌មានទាក់ទងនឹងការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកំណែទម្រង់រដ្ឋបាលសាធារណៈ

-បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងបានទូទាត់ការចំណាយផ្សេងៗ ចំនួន ២២៦សំណើ

-បានដោះស្រាយសំណើរផ្សេងៗ និងផ្គត់ផ្គង់វត្ថុអនុស្សាវរីយ៍ គ្រឿងបរិក្ខារ ប្រេងឥន្ធនៈ សម្ភារ-អនាម័យ សម្ភារការិយាល័យ ភេសជ្ជៈ និងអាហារសម្រន់សម្រាប់បម្រើដល់កិច្ចប្រជុំ សិក្ខាសាលា កម្មពិធីផ្សេងៗ និងជូនគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន ៧០សំណើ

-បានថតចម្លងឯកសារ ចំនួន ៦,១៣៤ច្បាប់ និងចងក្រងធ្វើជាសៀវភៅ ចំនួន ១០ក្បាល អស់ក្រដាសសរុបចំនួន ៧៥,៨៨៦សន្លឹក

-បានផ្តល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិ-ការដ្ឋានព្រឹទ្ធសភា ចុះបំពេញបេសកកម្មនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុង ចំនួន ១៦២លើក ស្មើនឹង ៥០៣នាក់

-បានរៀបចំសម្អាត តុបតែងលម្អសាលប្រជុំ បម្រើសេវាភេសជ្ជៈ អាហារសម្រន់ក្នុងកិច្ចប្រជុំ និងកម្មពិធីផ្សេងៗ ចំនួន ២៧លើក ស្មើនឹង ១,៣៩៦នាក់

-បានទទួលលិខិតចូល ចំនួន ២៤២ច្បាប់ និងបញ្ជូនលិខិតចេញ ចំនួន ៣៥៧ច្បាប់

-បានធ្វើលិខិតបេសកកម្មជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន ១៧ច្បាប់ ស្មើនឹង ៣៤នាក់ និងលិខិតអនុញ្ញាតច្បាប់ជូនសមាជិកព្រឹទ្ធសភា ចំនួន ០៥ច្បាប់

-បានចុះសួរសុខទុក្ខមន្ត្រីរាជការលំហែមាតុភាព និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន ០៤នាក់

-បានកែលម្អសួនច្បារ កាត់តម្រឹមស្មៅ មែកឈើ និងផ្កានានា ចំនួន ៤២លើក/ដើម ព្រមទាំងបាន ដាំដើមនិរតី និងដើមដៃមឹក ចំនួន ២៥០ដើម

-បន្តយកចិត្តទុកដាក់ការងាររក្សាអនាម័យ បរិស្ថាន សំរាម សួនច្បារ និងការដាំដើមឈើ ប្រព័ន្ធទឹក លូ ថ្នល់ ចំណតរថយន្ត ការងារសន្តិសុខ និងសណ្តាប់ធ្នាប់ ដើម្បីជានាឱ្យមានផាសុកភាព និង បរិស្ថានបៃតង

-បានទទួលលិខិតសុំអនុញ្ញាតច្បាប់មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងកត់ត្រាចូល ក្នុងសៀវភៅការងារ ចំនួន ៨៣ច្បាប់

-បានធ្វើសេចក្តីសម្រេច និងលិខិតបង្គាប់ការ ចំនួន ១២ច្បាប់

-បានធ្វើប័ណ្ណសម្គាល់ខ្លួន និងប័ណ្ណចេញ-ចូលក្នុងបរិវេណព្រឹទ្ធសភា ចំនួន ០២ប័ណ្ណ

-បានធ្វើតារាងបញ្ជាក់បៀវត្ស ប្រាក់បំណាច់ផ្សេងៗ លិខិតផ្តត់ផ្តង់ និងវិញ្ញាបនបត្របញ្ជាក់ រយៈពេលបំពេញការងាររដ្ឋ ចំនួន ០៨ច្បាប់

-បានធ្វើបញ្ជីរាយនាមមន្ត្រីរាជការស្នើសុំប្រាក់វិភាជន៍គ្រួសារ (ប្រពន្ធ-កូន) ប្រចាំខែធ្នូ ឆ្នាំ២០២៣ ចំនួន ០១នាក់

-បានបណ្តុះបណ្តាលធនធានមនុស្សក្នុងប្រទេស រួមមាន៖

- បើកវគ្គបណ្តុះបណ្តាលក្នុងស្ថាប័ន ចំនួន ០២វគ្គ មានសិក្ខាកាមចូលរួម ចំនួន ៧៩នាក់
- ចូលរួមសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលនៅក្រៅស្ថាប័ន ចំនួន ០៥វគ្គ មានសិក្ខាកាមចូលរួម ចំនួន ៥២នាក់

-បានបូកសរុបទិន្នន័យសម្រង់តម្រូវការបណ្តុះបណ្តាល ឆ្នាំ២០២៤ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បន្តធ្វើផែនការបណ្តុះបណ្តាល និងអភិវឌ្ឍធនធានមនុស្សរយៈពេល ១០ឆ្នាំ (ឆ្នាំ២០២១-២០៣០) របស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បានបំពាក់សម្ភារ បរិក្ខារ និងមធ្យោបាយដែលចាំបាច់បំផុតជាជំហានៗ ជូនអង្គភាពស្នូលដែល ត្រៀមរ៉ាប់រងការងារសំខាន់ៗនាពេលខាងមុខ

-បានបញ្ចប់ការសាងសង់របងថ្មីខាងមុខព្រឹទ្ធសភា និងការបំពាក់ជណ្តើរយន្តនៅអគារក្រហម និងការជួលជុលទីកន្លែងធ្វើការនៅអគារក្រហម អគារខុទ្ទកាល័យថ្នាក់ដឹកនាំ សាលសិក្ខាសាលាខាងត្បូង និងកែលម្អសួនច្បារ ព្រមទាំងបន្តកសាងខ្លោងទ្វារ (ច្រកចូល P3)

-បានសាងសង់ ជួសជុល កែលម្អអគារ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗរួមមាន៖

- បើកការដ្ឋានសាងសង់ខ្លោងទ្វារព្រឹទ្ធសភា (P4)
- ជួសជុលកែលម្អអគារថ្នាក់ដឹកនាំព្រឹទ្ធសភាទាំងបី
- ខាត់ និងលាបជញ្ជាំងខាងក្នុងបន្ទប់ប្រជុំនាយកដ្ឋានជំនួយការគណៈកម្មការព្រឹទ្ធសភា
- បិទស្កុតតាមជញ្ជាំង បង្អួច ទ្វារកញ្ចក់នៅបណ្ណាល័យ
- បញ្ចប់ការងារសាងសង់ឃ្លាំងនៅក្រោយអគារ D E

-បានជួសជុលកែលម្អហេដ្ឋារចនាសម្ព័ន្ធអគារ បណ្តាញទឹក បណ្តាញអគ្គិសនី, ត្រួតពិនិត្យជណ្តើរយន្ត សត្វកណ្តៀរ, រៀបចំ និងផ្លាស់ប្តូរគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិច គ្រឿងសង្ហារិម, ប្រមូលសម្ភារខូច, បិទលេខកូដសម្ភារសារពើភណ្ឌ, ប្រគល់ និងបំពាក់សម្ភារការិយាល័យជូនអង្គភាពចំណុះអគ្គ-លេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងជួសជុលហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀតក្នុងបរិវេណព្រឹទ្ធសភា ចំនួន ៩០០គ្រឿង/លើក

-បានប្រចាំការត្រួតពិនិត្យម៉ាស៊ីនភ្លើងនៅតាមសាលប្រជុំ និងការប្រើប្រាស់ទឹក ភ្លើងក្រោយម៉ោងរដ្ឋបាល និងថ្ងៃឈប់សម្រាក ចំនួន ៤០លើក

-បានធ្វើរបាយការណ៍ស្តីពី លទ្ធផលការងាររបស់ព្រឹទ្ធសភា ប្រចាំខែធ្នូ និងប្រចាំឆ្នាំ២០២៣ ទូលថ្វាយព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

-បានធ្វើសម្រង់ស្ថិតិ បទបង្ហាញ របាយការណ៍ស្តីពី លទ្ធផលការងារព្រឹទ្ធសភា និងអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែធ្នូ និងប្រចាំឆ្នាំ២០២៣ ព្រមទាំងបានផ្សព្វផ្សាយទៅតាមអង្គភាពចំណុះ-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងក្រសួង ស្ថាប័នពាក់ព័ន្ធនានា

-បានធ្វើរបាយការណ៍ស្តីពី ការពិនិត្យ និងតាមដានការអនុវត្តផែនការប្រតិបត្តិរបស់នាយកដ្ឋានចំណុះអគ្គនាយកដ្ឋានទាំង៩ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំត្រីមាសទី៤ ឆ្នាំ២០២៣

-បានទាក់ទងអ្នកជំនាញរៀបចំខ្សែកាមេរ៉ាសុវត្ថិភាពឡើងវិញ បន្ទាប់ពីរបងខាងមុខព្រឹទ្ធសភាសាងសង់រួច

-បានត្រួតពិនិត្យតាមកាមេរ៉ាសុវត្ថិភាពរាល់ថ្ងៃ ព្រមទាំងជួសជុល ប្តូរ និងថែទាំកាមេរ៉ាសុវត្ថិភាពជាប្រចាំ

-បានការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗដោយប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុង ចំនួន ២០លើក។

**៤.៣-ការងារសេវាច្បាប់៖**

-បានទទួលព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្ដីសម្រេច ប្រកាស របាយការណ៍ សេចក្ដីជូនដំណឹង និងលិខិតផ្សេងៗ ចំនួន ៤៣ច្បាប់

-បានធ្វើកំណត់បង្ហាញរបាយការណ៍សវនកម្ម ចំនួន ០៦ច្បាប់

-បន្តរៀបចំចងក្រងឯកសារកំណត់ហេតុសង្ខេប និងពិស្ដារនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងប្រជុំពេញអង្គព្រឹទ្ធសភា នីតិកាលទី៤ ឆ្នាំ២០២៣ ដើម្បីបោះពុម្ពធ្វើជាសៀវភៅ

-បានធ្វើបច្ចុប្បន្នភាពបញ្ជីសេចក្ដីព្រាងច្បាប់ ដែលព្រឹទ្ធសភាបានពិនិត្យ ហើយឱ្យយោបល់តាមឆ្នាំ និងនីតិកាលនីមួយៗ

-បានចងក្រងសម្រង់លទ្ធផលនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងសម័យប្រជុំព្រឹទ្ធសភា នីតិកាលទី៤ (ឆ្នាំ២០១៨-២០២៣) ដើម្បីបោះពុម្ពធ្វើជាសៀវភៅ

-បានបូកសរុបលទ្ធផលការងារព្រឹទ្ធសភា នីតិកាលទី៤ (ឆ្នាំ២០១៨-២០២៣) ដើម្បីបោះពុម្ពធ្វើជាសៀវភៅ។

**៤.៤-ការងារស្រាវជ្រាវ៖**

-បានសិក្សាផលទាក់ទងសេដ្ឋកិច្ច-សង្គម និងផលិតឯកសារជំនួយស្មារតីលើបទអន្តរាគមន៍លើសេចក្ដីព្រាងច្បាប់ ចំនួន ០៣ច្បាប់ ស្ដីពី៖

- ការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២
- ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤
- ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃអេមីរ៉ាតអារ៉ាប់រួម

-បានតាមដានរាល់ការចេញគោលនយោបាយ និងវិធានការរបស់រដ្ឋដែលពាក់ព័ន្ធនឹងសេដ្ឋកិច្ច-សង្គម

-បានតាមដាន និងសិក្សាស្រាវជ្រាវលើប្រធានបទ ចំនួន ០២ប្រធានបទ៖

- ការអនុវត្តការធ្វើកំណែទម្រង់គោលនយោបាយចំណូល-ចំណាយ
- ព្រឹត្តិបត្រស្ថិតិសេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុប្រចាំឆ្នាំ២០២៣

-បានចងក្រងទិន្នន័យ និងសូចនាករអប់រំសាធារណៈ ឆ្នាំ២០២២-២០២៣

-បានចងក្រងព័ត៌មានសភាអន្តរជាតិប្រចាំសប្ដាហ៍ ចំនួន ០៤ច្បាប់

-បានបំប្លែងឯកសារច្បាប់ និងលិខិតបទដ្ឋានគតិយុត្តតាមវិស័យទៅជាឯកសារឌីជីថល និងធ្វើបច្ចុប្បន្នភាពកម្រងច្បាប់ព្រឹទ្ធសភាក្នុងប្រព័ន្ធមូលទិន្នន័យ៖ ប្រមូល និងរៀបចំចងក្រងរាជកិច្ចពីលេខ៨០ ដល់លេខ៨៤ ឆ្នាំ២០២១

-បានផលិតព័ត៌មានច្បាប់ជាតិ និងអន្តរជាតិ ចំនួន ១៨អត្ថបទ

-បានផលិតព្រឹត្តិបត្រព័ត៌មានសេដ្ឋកិច្ច-សង្គមប្រចាំខែ (Research Journal)ស្តីពី វិបត្តិទឹកសកលលោក

-បានផលិតព្រឹត្តិបត្រស្រាវជ្រាវតាមវិស័យប្រចាំសប្តាហ៍ (Weekly E-Bulletin) ចំនួន ០៣ច្បាប់ និង ព្រឹត្តិបត្រព័ត៌មានសង្ខេប (Briefing Fact Sheet) ចំនួន ០៤ច្បាប់

-បានផលិតព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ចប្រចាំខែធ្នូ ឆ្នាំ២០២៣ ចំនួន ០៤ច្បាប់

-បានបញ្ចូលទិន្នន័យ (Budget Database System) ស្តីពី ថវិកាចំណូល-ចំណាយ សម្រាប់ខែកក្កដា ឆ្នាំ២០២៣ (TOFE) របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**៤.៥-ការងារព័ត៌មាន និងទំនាក់ទំនងសាធារណៈ៖**

-បានចុះត្រួតពិនិត្យ តាមដានប្រព័ន្ធ Network Internet Wi-Fi, ពង្រឹងពង្រីកការផ្គត់ផ្គង់ និងជួសជុល ឧបករណ៍ សម្ភារ បរិក្ខារបច្ចេកទេស ព្រមទាំងដោះស្រាយបញ្ហាផ្សេងៗដែលពាក់ព័ន្ធនឹងជំនាញបច្ចេក-វិទ្យាព័ត៌មាន ចំនួន ៧៦គ្រឿង/លើក

-បានបំពាក់ឧបករណ៍អេឡិចត្រូនិចមានដូចជា កុំព្យូទ័រយួរដៃ កុំព្យូទ័រលើតុ Ipad និង Printer ជូនសមាជិកព្រឹទ្ធសភា និងអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន ០៩គ្រឿង

-បានទទួលឯកសារ ទស្សនាវដ្តី ព្រឹត្តិបត្រ សៀវភៅច្បាប់ និងសៀវភៅជំនាញផ្សេងៗ ចំនួន ១០៤ក្បាល ព្រមទាំងបានបោះត្រាសៀវភៅ ដាក់លេខកូដសៀវភៅ ចុះបញ្ជីសៀវភៅ អ៊ុតក្រប-សៀវភៅ បិទប័ណ្ណខ្ចី និងសងសៀវភៅ ចំនួន ១៧៦ក្បាល

-បានរៀបចំបញ្ចូលឯកសារ សៀវភៅច្បាប់ សៀវភៅបោះពុម្ពដោយព្រឹទ្ធសភា និងអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភា និងសៀវភៅផ្សេងៗតាម https: ebook.senate-elibrary.com ចំនួន ២០ក្បាល

-បានរៀបចំបញ្ចូលទិន្នន័យឯកសារ និងសៀវភៅអង់គ្លេសក្នុងកម្មវិធីកូហា ចំនួន ២៣០ក្បាល

-បានបង្កើតផេក TikTok ជាផ្លូវការរបស់បណ្ណាល័យព្រឹទ្ធសភា ព្រមទាំងបានផ្សព្វផ្សាយឯកសារ និងសៀវភៅដែលមាននៅក្នុងបណ្ណាល័យព្រឹទ្ធសភា (ក្នុងនោះមានអ្នក Follower ចំនួន ០៧នាក់ និង អ្នក Like ចំនួន ១,៧០០នាក់)

-បានផលិត និងផ្សព្វផ្សាយវីដេអូព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងលទ្ធផលការងារព្រឹទ្ធសភា ចំនួន ១០លើក

-បានថត និងផ្សព្វផ្សាយព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងលទ្ធផលការងារព្រឹទ្ធសភា តាមប្រព័ន្ធFacebook, Instagram, Twitter, Youtube និងTiktok ចំនួន ៣៩៨លើក

-បានបញ្ចូលព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងលទ្ធផលការងារព្រឹទ្ធសភា លើគេហទំព័រព្រឹទ្ធសភា ចំនួន ១៤៤ប្រធានបទ

-បានប្រមូល និងផ្សព្វផ្សាយព័ត៌មានក្នុង Channel Telegram ព័ត៌មានប្រចាំថ្ងៃ ចំនួន ១,៩៤១ប្រធានបទ

-បានប្រមូល ដកស្រង់ ចងក្រង និងផ្សព្វផ្សាយព័ត៌មានសង្ខេបប្រចាំថ្ងៃ ចំនួន ២៩លើក និងទស្សនៈព័ត៌មានប្រចាំថ្ងៃ ចំនួន ១៣លើក

-បានរៀបចំផលិត Poster បុណ្យជាតិ ចំនួន ០២លើក

-បានតាំងពិព័រណ៍រូបភាពសកម្មភាពរបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា សមាជិក សមាជិកាគណៈកម្មការទាំង១០ ក្រុមភូមិភាគទាំង៨ និងក្រុមយន្តការនានារបស់ព្រឹទ្ធសភា នៅមុខអគារក្រហម និងខ្លោងទ្វារធំព្រឹទ្ធសភា ចំនួន ០៦លើក

-បន្តអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន សភាបៃតង សភាឌីជីថល រដ្ឋបាលអេឡិចត្រូនិច ប្រព័ន្ធសំឡេង ការផ្សព្វផ្សាយតាមបណ្តាញសង្គម បណ្ណាល័យ បណ្ណសារដ្ឋានអេឡិចត្រូនិច ការងារព័ត៌មាន ការផលិតវីដេអូ ការបោះពុម្ព និងការថតផ្សព្វផ្សាយអំពីសម័យប្រជុំព្រឹទ្ធសភា និងពិធីផ្សេងៗឱ្យបានលឿន ល្អ និងរលូន។

**៤.៦-ការងារពិធីការ និងទំនាក់ទំនងអន្តរជាតិ៖**

-បានរៀបចំចាត់ចែង និងសម្របសម្រួលជូនថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជួបពិភាក្សាការងារ ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ ចំនួន ១៤លើក

-បានកសាងជំនួយស្មារតី និងបកប្រែឯកសារនានា ចំនួន ០៣ច្បាប់/លើក

-បានតាមដាន និងចងក្រងសេចក្តីប្រកាសព័ត៌មាន និងសេចក្តីថ្លែងការណ៍របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ចំនួន ១២ច្បាប់

-បានផលិត និងផ្សព្វផ្សាយព្រឹត្តិបត្រព័ត៌មានកិច្ចការអន្តរជាតិប្រចាំឆ្នាំ២០២៣ ចំនួន ០១ច្បាប់

-បានចងក្រងឯកសារ បញ្ជីឈ្មោះអង្គការជាតិ និងអង្គការអន្តរជាតិ សេចក្តីប្រកាសព័ត៌មាន និងសេចក្តីថ្លែងការណ៍រួមរបស់អង្គការសង្គមស៊ីវិល និងក្រសួងនានា

-បានតុបតែងលម្អភ្លើងពណ៌ តាំងព្រះឆាយាលក្ខណ៍អមដោយហ្វុងអក្សរនៅខាងមុខស្ថាប័នព្រឹទ្ធសភា។

**៤.៧-ការងារអគ្គាធិការដ្ឋាន៖**

-បានប្រជុំពិភាក្សាការងារអំពីលទ្ធផលការងារសង្គមកិច្ច និងការផ្តល់សេវាជាមួយអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែធ្នូ ឆ្នាំ២០២៣ ចំនួន ១៩លើក

-បានប្រជុំពិភាក្សាការងារជាមួយអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងធ្វើរបាយការណ៍ស្តីពី ការអនុវត្តផែនការការងារ និងគោលនយោបាយនានារបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បានចុះត្រួតពិនិត្យជាក់ស្តែងតាមនាយកដ្ឋាន ចំនួន ០២លើក ដើម្បីផ្ទៀងផ្ទាត់បញ្ជីវត្តមានដែលនាយកដ្ឋានចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបញ្ជូនមកនាយកដ្ឋានគ្រប់គ្រងផ្ទៃក្នុងនៃអគ្គាធិការដ្ឋានរៀងរាល់ថ្ងៃ និងរបាយការណ៍ជូនថ្នាក់ដឹកនាំ

-បានបូកសរុប និងធ្វើរបាយការណ៍សម្រង់វត្តមានប្រចាំថ្ងៃ ចំនួន ២២លើក ប្រចាំសប្តាហ៍ ចំនួន ០២លើក និងប្រចាំខែធ្នូ ឆ្នាំ២០២៣

-បានចុះត្រួតពិនិត្យ និងធ្វើរបាយការណ៍ស្តីពី បរិស្ថាន អនាម័យ ការខូចខាតសម្ភារតាមអគារ និងសណ្តាប់ធ្នាប់នៃការចតយានយន្តក្នុងបរិវេណព្រឹទ្ធសភា

-បានធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះមន្ត្រីរាជការតាមអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បានធ្វើរបាយការណ៍ស្តីពី លទ្ធផលការងាររបស់នាយកដ្ឋានត្រួតពិនិត្យការងារសង្គមកិច្ច និងការផ្តល់សេវាប្រចាំខែធ្នូ ឆ្នាំ២០២៣។

**II-ទិសដៅការងារខែមករា ឆ្នាំ២០២៤**

-បរិបទនៃការឈានទៅការបោះឆ្នោតព្រឹទ្ធសភា នីតិកាលទី៥ នាថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២៤

-ត្រៀមការងារបញ្ចប់នីតិកាលទី៤ សម្រាប់ដំណាក់កាលដំណាច់ឆ្នាំ២០២៣ និងដើមឆ្នាំ២០២៤

-ត្រៀមរៀបចំបើកសម័យប្រជុំដំបូងព្រឹទ្ធសភា នីតិកាលទី៥

-ត្រៀមការងារឆ្លោះទៅនីតិកាលទី៥ ព្រឹទ្ធសភា ក្នុងត្រីមាសទី១ ឆ្នាំ២០២៤

-ត្រៀមបត់បែនដើម្បីប្រឈមនឹងការគំរាមកំហែងថ្មីៗ ជំងឺរាតត្បាតថ្មី និងគ្រោះធម្មជាតិ

-បន្តប្រឈមការប្រែប្រួលអាកាសធាតុ ផលវិបាកសេដ្ឋកិច្ច សង្គម វប្បធម៌ បរិស្ថាន សភាពការណ៍តំបន់ និងពិភពលោកប្រែប្រួលពុំទៀងទាត់ និងស្មុគស្មាញ

-ធានាប្រសិទ្ធភាព ប្រសិទ្ធផល សុវត្ថិភាពនៃការដឹកនាំ និងគ្រប់គ្រងប្រព័ន្ធការងាររដ្ឋបាល ហិរញ្ញវត្ថុ បច្ចេកទេស ព័ត៌មាន សន្តិសុខ បច្ចេកវិទ្យា នីតិវិធី ពិធីការ ការស្រាវជ្រាវ ទំនាក់ទំនងក្នុង-ក្រៅស្ថាប័ន និងក្នុង-ក្រៅប្រទេស ព្រមទាំងជំនួយកិច្ចសហប្រតិបត្តិការនានា

-បន្តយកចិត្តទុកដាក់បរិស្ថាន អនាម័យ សួនច្បារ សំរាម ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត អគារការិយាល័យ សន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។

**១- មុខងារនីតិកម្ម**

-ត្រៀមរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ប្រជុំពេញអង្គ និងប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៤

-ត្រៀមរៀបចំឯកសារគោលការណ៍ជាមូលដ្ឋានសម្រាប់ការងារសំខាន់ៗសម្រាប់ព្រឹទ្ធសភា នីតិកាលទី៥។

**២-មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា**

-ត្រៀមសហការ និងសម្របសម្រួលការងារជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា ជួបសវនាការ ពិភាក្សាការងារជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា និងការចុះបេសកកម្មនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា។

**៣- មុខងារតំណាង**

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អញ្ជើញចូលរួមទិវាជ័យជម្នះ៧មករា លើរបបប្រល័យពូជសាសន៍

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា អញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋនៅមូលដ្ឋាន ពិភាក្សាការងារជាមួយអាជ្ញាធរដែនដី ចូលរួមពិធីសាសនា និងពិធីផ្លូវការផ្សេងៗ នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា

-ត្រៀមរៀបចំជូនគណៈកម្មការទី៤ព្រឹទ្ធសភា ចូលរួមពិធីសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំនៅស្រុករុក្ខគិរី ខេត្តបាត់ដំបង

-ត្រៀមរៀបចំជូនគណៈកម្មការទី៥ព្រឹទ្ធសភា ចូលរួមពិធីសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ-សង្កាត់តាមបណ្តាក្រុង ស្រុក នៅខេត្តតាកែវ ខេត្តកំពត និងខេត្តកែប

-ត្រៀមរៀបចំជូនក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ ចូលរួមវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សារាជធានីភ្នំពេញ អាណត្តិទី៣ ឆ្នាំ២០២៣ នៅខណ្ឌជ្រោយចង្វារ ខណ្ឌមានជ័យ ខណ្ឌពោធិ៍សែនជ័យ ខណ្ឌ៧មករា និងខណ្ឌសែនសុខ

-ត្រៀមទទួលដំណើរទស្សនកិច្ចរបស់សាធារណជន និងយុវជនមកកាន់ព្រឹទ្ធសភា។

**៤- មុខងារសហប្រតិបត្តិការអន្តរជាតិ**

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំព្រឹទ្ធសភា ក្នុងពិធីជំនួបជាមួយឥស្សរជនជាន់ខ្ពស់បរទេស និងអគ្គទូតនានានៃប្រទេសជាមិត្ត

-ត្រៀមរៀបចំបែបបទជូនគណៈប្រតិភូព្រឹទ្ធសភា អញ្ជើញទៅបំពេញទស្សនកិច្ចនៅព្រះរាជាណាចក្រជប៉ុន សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋសង្គមនិយមវៀតណាម និងសាធារណរដ្ឋ-ប្រជាធិបតេយ្យប្រជាមានិតឡាវ (ករណីតម្រូវការនីតិកាលថ្មី)

-ត្រៀមរៀបចំជូនសមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការព្រឹទ្ធសភា ចូលរួមប្រជុំក្នុងកិច្ចប្រជុំតំបន់ និងអន្តរជាតិ កិច្ចប្រជុំវេទិកា

-ផ្តល់សេវាចាំបាច់បម្រើការងារសហប្រតិបត្តិការតំបន់ និងអន្តរជាតិ ការចូលរួមមហាសន្និបាត សិក្ខាសាលា វេទិកានានា កម្មវិធីជំនួប កម្មវិធីផ្លូវការ ការស្វែងរកជំនួយ និងកិច្ចសហប្រតិបត្តិការជាមួយដៃគូសំខាន់ៗ

-ជំរុញកម្មវិធីបណ្តុះបណ្តាលមន្ត្រីក្នុង និងក្រៅប្រទេស តាមកម្មវិធីសហប្រតិបត្តិការជាមួយភាគីជាមិត្ត និងដៃគូអភិវឌ្ឍផ្សេងៗទៀត

-បន្តសកម្មភាពសហប្រតិបត្តិការជាមួយដៃគូនានា ដើម្បីអនុវត្តយុទ្ធសាស្ត្រថវិកាតិច សកម្មភាពច្រើន ព្រមទាំងការស្វែងរកជំនួយសម្រាប់នីតិកាលថ្មី

-ត្រៀមរៀបចំការប្រជុំជូនក្រុមយន្តការនានារបស់ព្រឹទ្ធសភាតាមប្រព័ន្ធវីដេអូ និងដោយផ្ទាល់

-ត្រៀមធ្វើលិខិតអបអរសាទរទិវាបុណ្យជាតិ នៃប្រទេសអូស្ត្រាលី និងសាធារណរដ្ឋឥណ្ឌា

-បន្តត្រៀមស្រាវជ្រាវ បកប្រែ និងផលិតឯកសារជំនួយស្មារតី សុន្ទរកថាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជួបជាមួយភ្ញៀវអន្តរជាតិ ក្នុងជំនួបសវនាការ កិច្ចប្រជុំ និងទស្សនកិច្ចនានា

-តាមដាន និងក្រើនរំលឹកសំណើសុំជំនួយពីប្រទេសជាមិត្ត និងដៃគូនានា។

**៥- មុខងារអភិវឌ្ឍន៍ស្ថាប័ន**

-គ្រប់អង្គភាពត្រូវបញ្ចប់ការកសាងផែនការប្រតិបត្តិឆ្នាំ២០២៤ ហើយអនុវត្តផែនការនេះឱ្យមានប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់ ឆ្លើយតបបានទៅនឹងចក្ខុវិស័យរបស់ផែនការយុទ្ធសាស្ត្រ (២០២១-២០៣០)

-ត្រៀមធ្វើរបាយការណ៍ស្តីពី សកម្មភាព និងលទ្ធផលការងាររបស់ព្រឹទ្ធសភានៅចន្លោះសម័យប្រជុំលើកទី១១ និងលើកទី១២ នីតិកាលទី៤

-គ្រប់អង្គភាពពាក់ព័ន្ធត្រៀមធ្វើរបាយការណ៍តាមវិស័យ និងរបាយការណ៍ស្តីពី សកម្មភាពការងាររបស់ព្រឹទ្ធសភានៅចន្លោះសម័យប្រជុំ ឱ្យបានល្អ និងទាន់ពេលវេលា

-បន្តប្រជុំពិនិត្យ និងពិភាក្សាគោលការណ៍ណែនាំរួមស្តីពី ការគ្រប់គ្រងហិរញ្ញវត្ថុរបស់ព្រឹទ្ធសភា

-ត្រៀមរៀបចំកញ្ចប់ថវិកាឆ្នាំ២០២៤ របស់ព្រឹទ្ធសភា សម្រាប់បម្រើរចនាសម្ព័ន្ធនយោបាយ និងរចនាសម្ព័ន្ធរដ្ឋបាល

-ត្រៀមរបាយការណ៍ទូទាត់ថវិកាព្រឹទ្ធសភា ប្រចាំឆ្នាំ២០២៣ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

-ត្រៀមបើកប្រាក់បៀវត្សសម្រាប់ខែមករា ឆ្នាំ២០២៤ ប្រាក់ឧបត្ថម្ភ និងផលប្រយោជន៍ផ្សេងៗជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា និងភ្នាក់ងារសន្តិសុខនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ឱ្យបានទាន់ពេលវេលា

-ត្រៀមទូទាត់ថវិកាចុងក្រោយដំណាច់នីតិកាលទី៤ របស់គណៈកម្មការ ក្រុម និងយន្តការនានា ចំណុះព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-ត្រៀមរៀបចំប្រាក់បៀវត្សរបស់សមាជិកព្រឹទ្ធសភាចូលនិវត្តន៍ ការបញ្ចប់របបជំនួយការ និងអ្នកបើកបរដោយឡែក

-ត្រៀមរៀបចំផែនការលំអិតសភាបៃតង និងសភាឌីជីថល ដើម្បីសុំហិរញ្ញប្បទាន ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមឆ្នាំនីមួយៗ

-ចាប់ផ្ដើមអនុលោមតាមបរិបទបរិស្ថានទំនើបបៃតងដែលប្រឆាំងការប្រែប្រួលអាកាសធាតុ (ការគ្រប់គ្រងសំរាម ប្លាស្ទិក ការដាំដើមឈើកែលម្អបរិស្ថាន និងកន្លែងធ្វើការ ព្រមទាំងការបំពាក់អំពូលព្រះអាទិត្យ)

-ស្នើសុំឥណទាន ការបំពាក់Solar (គម្រោងបៃតង) និងការរំដោះទឹកភ្លៀងចេញពីបរិវេណព្រឹទ្ធសភា

-បន្តតាមដានជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្ថានទូតចិន ស្ថានទូតវៀតណាម ទីប្រឹក្សាសេដ្ឋកិច្ច និងពាណិជ្ជកម្មចិន ប្រចាំព្រះរាជាណាចក្រកម្ពុជា លើគម្រោងស្នើកសាងអគារ ជំនួយ និងសម្ភារ បរិក្ខារ សម្រាប់បម្រើនីតិកាលថ្មី

-ត្រៀមរៀបចំគោលការណ៍ គោលនយោបាយថ្មីៗ ស្របតាមដំណើរការងារ និងការវិវដ្តថ្មីៗ

-គ្រប់អគ្គនាយកដ្ឋាន នាយកដ្ឋាន និងគ្រប់អង្គភាព ត្រូវរៀបចំបច្ចុប្បន្នភាព កំណត់តួនាទី ភារកិច្ច សមត្ថកិច្ច ឱ្យកាន់តែសុក្រឹត ព្រមទាំងអនុវត្តការធ្វើពិពណ៌នាតួនាទី ភារកិច្ចរបស់មន្ត្រីម្នាក់ៗ (Job Description) ឡើងវិញស្របតាមការប្រែប្រួលថ្មីចុងក្រោយនេះ

-បន្តការពង្រឹងវិន័យ និងគោលនយោបាយសន្សំសំចៃរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា 3E's

-ត្រៀមផ្តល់គ្រឿងឥស្សរិយយស និងមេដាយការងារជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដែលមានស្នាដៃសម្រាប់ឆ្នាំ២០២២ និងឆ្នាំ២០២៣

-បន្តធ្វើបច្ចុប្បន្នភាពផែនការការងារសម្រាប់ការត្រៀមទទួលនីតិកាលទី៥ របស់ព្រឹទ្ធសភា

-បន្តបណ្តុះបណ្តាលថ្នាក់ដឹកនាំ និងមន្ត្រីនាយកដ្ឋាននៅនឹងកន្លែងពាក់ព័ន្ធនឹងការអនុវត្តការងារប្រចាំថ្ងៃរបស់នាយកដ្ឋាននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភានីមួយ

-ត្រៀមបើកវគ្គបណ្តុះបណ្តាលលើមុខជំនាញដែលជាតម្រូវការចាំបាច់របស់ស្ថាប័នរួមមាន៖

- វគ្គ "ឯកសារស្រាវជ្រាវផ្នែកច្បាប់"
- វគ្គ "ការស្រាវជ្រាវកិច្ចការសភា និងគ្រូបង្គោលលើជំនាញស្រាវជ្រាវសភា"
- វគ្គ "វិធីសាស្ត្របញ្ជ្រាបសមភាពយេនឌ័រនៅក្នុងការងារសភា"
- វគ្គ "ស្រាវជ្រាវថវិកា"

-ការបណ្តុះបណ្តាលក្នុងក្របខ័ណ្ឌ (APF) ព្រមទាំងអាហារូបករណ៍សិក្សានៅសាធារណរដ្ឋឥណ្ឌា, សាធារណរដ្ឋប្រជាមានិតចិន, ព្រះរាជាណាចក្រជប៉ុន និងប្រទេសជាមិត្តផ្សេងទៀត

-ត្រៀមបញ្ជូនមន្ត្រីរាជការទៅបណ្តុះបណ្តាលនៅសាលាភូមិន្ទរដ្ឋបាលឆ្នាំ២០២៤

-អនុវត្តគម្រោងសាលប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ថ្មី និងសាលប្រជុំពេញអង្គបណ្តោះអាសន្ន

-ជួសជុល និងបំពាក់សម្ភារនៅសាលប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងសាលជំនួបសម្រាប់ធ្វើជាការិយាល័យថ្នាក់ដឹកនាំព្រឹទ្ធសភាថ្មី និងសាលជំនួបថ្មី

-បន្តការងារជួសជុលថែទាំអគារ ជួសជុលអគារក្រហម អគារថ្នាក់ដឹកនាំព្រឹទ្ធសភា អគារសមាជិកព្រឹទ្ធសភា និងផ្លាស់ប្តូរគ្រឿងបរិក្ខារផ្សេងៗនៅតាមអគារនានា ហេដ្ឋារចនាសម្ព័ន្ធអេឡិចត្រូនិច ប្រព័ន្ធ-សំឡេង ប្រព័ន្ធអគ្គិសនី និងប្រព័ន្ធម៉ាស៊ីនត្រជាក់

-លើកកម្ពស់សមត្ថភាពប្រើប្រាស់ និងថែទាំបច្ចេកទេស គ្រប់គ្រងការប្រើប្រាស់កម្លាំង សម្ភារ និងបច្ចេកវិទ្យាព័ត៌មានឱ្យបានសមស្របតាមការប្រែប្រួល និងតម្រូវការថ្មី ដោយធានាបានសន្តិសុខ សុវត្ថិភាព វឌ្ឍនភាព និងនិរន្តរភាព

-ការវិនិយោគលើវិស័យបច្ចេកវិទ្យាព័ត៌មាន និងវិស័យបច្ចេកទេស គឺជាស្នូលសំខាន់នៃការអភិវឌ្ឍស្ថាប័ន និងការលើកកម្ពស់សមត្ថភាពលើគ្រប់វិស័យ ព្រមទាំងជំនាញរបស់មន្ត្រី បុគ្គលិក

-បន្តកសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យ គ្រប់គ្រងព័ត៌មាន គ្រប់គ្រងរដ្ឋបាល កម្មវិធីបណ្ណសារអេឡិច-ត្រូនិច និងបណ្ណាល័យអេឡិចត្រូនិច ព្រមទាំងការចូលរួមវគ្គផ្សេងៗរៀបចំដោយសភានៃប្រទេសជាមិត្ត

-បន្តតាមដាន និងចងក្រងព័ត៌មានសំខាន់ៗនៅក្នុងតំបន់ និងអន្តរជាតិ ពាក់ព័ន្ធនឹងស្ថានភាពនយោបាយ សន្តិសុខ សេដ្ឋកិច្ច វប្បធម៌ និងពាណិជ្ជកម្ម

-បន្តការរក្សាទុកឯកសារក្នុងប្រព័ន្ធឌីជីថល (Digital) និងគួបផ្សំជាក្រដាស

-ត្រៀមរៀបចំផលិតខ្សែវីដេអូព័ត៌មានរបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

**III-សេចក្តីសន្និដ្ឋាន**

ក្នុងខែធ្នូនេះ ជាខែចុងបញ្ចប់នៃឆ្នាំ២០២៣ ទាំងថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានខិតខំប្រឹងប្រែងយ៉ាងយកចិត្តទុកដាក់ ដើម្បីបិទបញ្ចប់ការអនុវត្តផែនការប្រតិបត្តិឆ្នាំ២០២៣ និងបានកសាងផែនការប្រតិបត្តិឆ្នាំ២០២៤ ដោយរក្សាបានស្មារតីបុរេសកម្ម ដើម្បីធានាឱ្យការងារប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់ជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភាបំពេញមុខងាររបស់ខ្លួន។

ស្របពេលជាមួយគ្នានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានយកចិត្តទុកដាក់ផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា បំពេញមុខងាររបស់ខ្លួនបានល្អ និងទាន់ពេលវេលា។ ជាពិសេសបានផ្តល់

អាទិភាពលើមុខងារតំណាងដែលតម្រូវការចាំបាច់ក្នុងការឈានឆ្ពោះទៅកាន់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នាថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២៤។

ទន្ទឹមនឹងការងារនេះ ហើយក្នុងពេលតែមួយ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបាននឹងកំពុងបន្តឈរយ៉ាងរឹងមាំប្រឈមជាមួយការដ្ឋានការងារសំខាន់ៗចំនួនបីគឺ ការបោះឆ្នោតព្រឹទ្ធសភា ការបញ្ចប់នីតិកាលទី៤ និងការចាប់ផ្តើមនីតិកាលទី៥ ដែលយើងទាំងអស់គ្នាត្រូវធានាឱ្យបានទូវការងារទាំងអស់បានប្រព្រឹត្តទៅដោយរលូនទាន់ពេលវេលាកំណត់។

គ្រប់ការដ្ឋានការងារត្រូវអនុវត្តដោយសកម្ម ពេញលេញជាមួយនឹងការបំពាក់មូលដ្ឋានសំខាន់ៗ រដ្ឋបាល បច្ចេកទេស បច្ចេកវិទ្យា នីតិវិធី ពិធីការ ហើយបទដ្ឋាន គោលការណ៍ ត្រូវរក្សាកម្រិតខ្ពស់ដើម្បីដំណើរការរលូននៃនីតិកាលទី៥ ខាងមុខនេះ។

ថ្ងៃអង្គារ ៦រោច ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី០២ ខែមករា ឆ្នាំ២០២៤

**អគ្គលេខាធិការ**

អ៊ុំ_សារិទ្ធ